ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សាលាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៧៣

ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩

សាលដីកា

លេខ ១៦ "III"

ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រមរបាយការណ៍

## ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ឋានៈជាអគ្គព្រះរាជអាជ្ញារង

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៥៧ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ចន្ទលីដូ ដែលប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ២០ ក្រII "វ" ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលមាន៖

## បុគ្គលប្តឹងសាទុក្ខ

១-ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីដូ ភេទស្រី កើតនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ។

-លោក [redacted] ណាដូ និងលោក [redacted] ច័ន្ទតារាវុធ ជាមេធាវីការពារ ។

Scanned with CamScanner

២-ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទសុទ្ធា ភេទប្រុស អាយុ ៣៣ ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅសង្កាត់អូរឫស្សី៤ ក្រុងភ្នំពេញ និងទីលំនៅបច្ចុប្បន្ននៅផ្ទះ [redacted] រាជធានីភ្នំពេញ ។

ជាប់ចោទពីបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនសេះមាស និងក្រុមហ៊ុនអេសឃេអេ (SKA) ផ្ទះលេខ AH1-2-3 ភូមិក្បាលដំរី សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៩, មាត្រា៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណី ៖ ឈ្មោះ [redacted] ផល្លី ភេទស្រី អាយុ ៧១ ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ។

-លោក [redacted] សាវុឌ្ឍី និងលោក [redacted] វណ្ណយ ជាមេធាវីការពារ ។

<u>**អំពីអង្គហេតុ៖**</u>

ឈ្មោះ [redacted] ច័ន្ទសុទ្ធា បានចូលបម្រើការងារនៅក្រុមហ៊ុនសេះមាស និងក្រុមហ៊ុនអេសឃេអេ (SKA) ដោយមានការជឿទុកចិត្ត ខាងក្រុមហ៊ុនបានប្រគល់តួនាទីឱ្យជនជាប់ចោទឈ្មោះ [redacted] ច័ន្ទសុទ្ធា មានតួនាទីជាជំនួយការនាយក ជាប្រធានទីផ្សារ និងជាប្រធានគណនេយ្យ ។ រហូតដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥ នៅចំណុចក្រុមហ៊ុនសេះមាស និងក្រុមហ៊ុនអេសឃេអេ (SKA) ផ្ទះលេខ AH1-2-3 ភូមិក្បាលដំរី សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ តំណាងក្រុមហ៊ុនបានរកឃើញថា ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទសុទ្ធា ដែលជាបុគ្គលិករបស់ក្រុមហ៊ុនសេះមាស និងក្រុមហ៊ុនអេសឃេអេ (SKA) បានកិបកេងលុយក្រុមហ៊ុនសរុបចំនួន ១២០.០០០ (មួយរយម្ភៃពាន់) ដុល្លារអាមេរិក រួចឱ្យជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ (ដែលជាប្រពន្ធរបស់ឈ្មោះ [redacted] ច័ន្ទសុទ្ធា) យកលុយទៅទិញផ្ទះលេខ C-53 មហាវិថីសហព័ន្ធរុស្ស៊ី ផ្លូវឈៀហ្វលណេស ភូមិទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ហើយជនជាប់ចោទឈ្មោះ [redacted] ច័ន្ទសុទ្ធា បាន គេចខ្លួនបាត់ ដែលខាងក្រុមហ៊ុនមិនអាចទាក់ទងបាន ។ ក្នុងអំឡុងពេលដែលជនជាប់ចោទឈ្មោះ [redacted] ច័ន្ទ សុទ្ធា គេចខ្លួន ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ បានធ្វើឯកសារលែងលះ ដើម្បីបង្វែរពីទ្រព្យសម្បត្តិរួម មកធ្វើជាទ្រព្យរបស់ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ តែម្នាក់ឯងក្នុងបំណងគេចវេសពីការសងលុយទៅឱ្យក្រុមហ៊ុនវិញ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៤៣៧ "ញ" ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោស

ក-ឈ្មោះ [redacted] ច័ន្ទសុទ្ធា ភេទប្រុស ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់ ១៨ (ដប់ប្រាំបី) ខែ ។

Scanned with CamScanner

ពីបទរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនសេះមាស និងក្រុមហ៊ុនអេសឃេអេ (SKA) ផ្ទះលេខ AH1-2-3 ភូមិក្បាលដំរី សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២-ឈ្មោះ [redacted] ច័ន្ទលីជូ ភេទស្រី ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់ ០៦ (ប្រាំមួយ) ខែ តែទោសនេះឱ្យជនជាប់ចោទអនុវត្តទោសព្យួរទាំងស្រុង តាមបញ្ញត្តិមាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

ពីបទសមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនសេះមាស និងក្រុមហ៊ុន អេសឃេអេ (SKA) ផ្ទះលេខ AH1-2-3 ភូមិក្បាលដំរី សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩, មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

II-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ច័ន្ទសុទ្ធា តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

III-បង្គាប់ឱ្យឈ្មោះ [redacted] ច័ន្ទសុទ្ធា និងឈ្មោះ [redacted] ច័ន្ទលីជូ រួមគ្នាសងសំណងការខូចខាតចំនួន ១២០.០០០ (មួយរយម្ភៃពាន់) ដុល្លារអាមេរិក និងសំណងជំងឺចិត្តចំនួន ១០.០០០.០០០ (ដប់លាន) រៀល ។ (ការទាមទារលើសពីនេះបដិសេធចោល) ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលារសៀល និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ វេលារសៀល ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ច័ន្ទសុទ្ធា ។

ទុកសិទ្ធិប្តឹងទាស់និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ២១ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ ក្នុងការប្តឹងឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៤៣៧ "ញ" ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

សាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ២០ ក្រII "វ" ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៤៣៧ "ញ" ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ, មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ។



Scanned with CamScanner

បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៥៧ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ ក្នុងការប្តឹងសាទុក្ខ បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ២០ ក្រII "រ" ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍អានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋាននិងប្តឹងសុំថា ៖ ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ ត្រូវចោទប្រកាន់ពីបទសមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត តាមបញ្ញត្តិមាត្រា២៩, មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។ នៅក្នុងសារណារបស់លោក [redacted] ណាដូ និង លោក [redacted] ច័ន្ទតារាវុធ ជាមេធាវីការពារឱ្យជនជាប់ចោទលើកឡើងថា ៖

១-ឈ្មោះ [redacted] ច័ន្ទលីជូ មិនមែនជាបុគ្គលិកបម្រើការនៅក្នុងក្រុមហ៊ុន ដូច្នេះគ្មានលទ្ធភាពក្នុងការជួយសម្រួល ផ្តល់ជំនួយ ដូចក្នុងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌនោះទេ ។

៣-ពុំមានភស្តុតាងថាឈ្មោះ សាយ ច័ន្ទលីជូ បានប្រព្រឹត្តអំពើសមគំនិតជាមួយឈ្មោះ [redacted] ច័ន្ទសុទ្ធា នោះទេ ។

៣-កិច្ចសន្យាលក់ទិញផ្ទះ និងទំនាក់ទំនងអាពាហ៍ពិពាហ៍ មិនមែនជាភស្តុតាងបញ្ជាក់អំពីការសមគំនិតនោះទេ ។

៤-ពុំមានធាតុផ្សំនៃបទល្មើសតាមមាត្រា៣៩១, មាត្រា ៣៩២ និងមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ ។

៥-មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ" ។

ការលើកឡើងខាងលើនេះមានមូលហេតុសមស្របដែលគប្បីក្រុមប្រឹក្សាពិចារណា ។ តំណាងមហាអយ្យការទុកជូនក្រុមប្រឹក្សាសម្រេចតាមច្បាប់ ។

-ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ បានឆ្លើយថា ៖ ពីដំបូងឡើយខ្លួនទាក់ទងជាមួយគ្រួសារខ្លួន គឺដើមបណ្តឹងចូលធ្វើជាមេបាចូលស្តីដណ្តឹងខ្លួន ។ គ្រួសាររបស់ខ្លួនគឺជាកូនចិញ្ចឹមរបស់ដើមបណ្តឹង ។ ពួកគាត់ជាមេបា ហើយក៏ជាអ្នកប្តឹងខ្លួនដែរ ។ ខ្លួនបានរៀបការក៏បានទិញផ្ទះ ហើយក៏មិនមែនជាលុយរបស់ខ្លួនផ្ទាល់នោះទេ គឺលុយរបស់ម៉ាក់ប៉ារបស់ខ្លួនជាអ្នកទិញ ដោយសារតែប៉ាម៉ាក់របស់ខ្លួនជាអ្នករកស៊ី គាត់មិនមានលទ្ធភាពទៅធ្វើការបង់រំលស់ ដល់ពេលអញ្ចឹងបានពឹងពាក់គ្រួសាររបស់ខ្លួនដែលជាអ្នកធ្វើការនៅក្នុងក្រុមហ៊ុន គឺដាក់ឯកសារឱ្យធ្វើការបង់រំលស់ដោយដាក់ឈ្មោះខ្លួននិងប្តី ។ ពេលបង់រំលស់ដាច់នៅឆ្នាំ២០១៣ ហើយក្រោយមកទៀតនៅឆ្នាំ២០១៤ ទើបគ្រួសាររបស់ខ្លួនបានលួងលោមខ្លួនឱ្យរត់ឯកសារប្តង់ផ្ទះនៅធនាគារដើម្បីយកលុយរកស៊ី ។ ក្នុងអំឡុងឆ្នាំ២០១៥ ខ្លួនចាប់បានដោយគ្រួសារលួចមានស្រី និងកូន ។ ខ្លួនមិនបានពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុនសេះមាសនោះទេ ។ ខ្លួនមិនបានដឹងពីផ្ទៃក្នុងរបស់ក្រុមហ៊ុនយ៉ាងម៉េចនោះទេ ។ នៅថ្ងៃដែលខ្លួនបានដឹងថា



Scanned with CamScanner

ប្ដីរបស់ខ្លួនមានស្រី បានគេមកប្ដឹងថា ខ្លួនសមគំនិតជាមួយអតីតប្ដីខ្លួនថា បោកយកលុយទិញផ្ទះ ។ ខ្លួនមានមុខរបរជាអ្នកលក់ អីវ៉ាន់ ស្បែកជើង ខោអាវ នៅផ្សារឃ្លាំងរំសេវ។ ក្រោយបែកគ្នាមកខ្លួនមិនបានរកស៊ីលក់អីវ៉ាន់អញ្ចឹងទៀតទេ ខ្លួនរកស៊ីក្រៅ ។

លោក [redacted] ច័ន្ទសុទ្ធា ដែលជាអតីតប្ដីរបស់ខ្លួនបានរៀបការជាមួយគ្នានៅក្នុងឆ្នាំ២០១២ ។ នៅពេលដែលខ្លួនបានស្គាល់ជាមួយលោក [redacted] ច័ន្ទសុទ្ធា គឺគាត់បានចូលធ្វើការនៅក្នុងក្រុមហ៊ុនសេះមានទេះរួចហើយ ។ មានន័យថា ធ្វើការនៅក្នុងក្រុមហ៊ុនមុនរៀបការទៀត (ប្រហែល៥ ឬ ៦ ឆ្នាំមុនរៀបការ) ។ ខ្លួនបានរៀបការហើយបានទិញផ្ទះ ។ រៀបការបានប្រហែលក្នុងឆ្នាំ២០១៣ ខ្លួនបានទិញផ្ទះដាក់ឈ្មោះខ្លួនជាមួយប្ដីរបស់ខ្លួនគឺឈ្មោះ [redacted] ច័ន្ទសុទ្ធា ។ មុខរបររបស់ខ្លួននៅឃ្លាំងរំសេវ គឺក្នុងឆ្នាំ២០០៨ ដែលជារបស់បងស្រីរបស់ខ្លួន ។ ខ្លួនបានបែកគ្នាប្រហែល ៥ ឆ្នាំមកហើយ ។ ប្រាក់ចំណូលនៅដែលលក់នៅផ្សារបានប្រហែលជាងមួយពាន់ និងលក់តាមអនឡាញប្រហែលជាងពីរពាន់ ក្នុងមួយខែ ។ ផ្ទះបង់រំលស់ពីរនាក់ប្ដីប្រពន្ធដែលឈរឈ្មោះ តែជាក់ស្ដែងគឺប៉ាម៉ាក់របស់ខ្លួនជាអ្នកបង់រំលស់ឱ្យ ។ ដោយសារតែប៉ាម៉ាក់របស់ខ្លួនជាអ្នករកស៊ី ពិបាកធ្វើឡូន ហើយគ្រួសាររបស់ខ្លួនជាអ្នកធ្វើការនៅក្នុងក្រុមហ៊ុន ងាយស្រួលរត់ការ ។ ផ្ទះបង់រំលស់ចូលមួយខែជាងមួយពាន់ ។ ផ្ទះបង់ចប់នៅក្នុងឆ្នាំ២០១៣ ហើយបានយកទៅដាក់នៅធនាគារតទៀត ។

-លោក [redacted] ណាដូ ជាមេធាវីការពារបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ខ្លួនជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីដូ ខ្លួនសូមរក្សាតាមខ្លឹមសារដូចមានក្នុងសារណាការពារ ។ ទី១.ពាក់ព័ន្ធនឹង [redacted] ច័ន្ទលីដូ និងគ្រួសារ ។ ឈ្មោះ [redacted] ច័ន្ទលីដូ ជាអតីតភរិយារបស់ឈ្មោះ [redacted] ច័ន្ទសុទ្ធា ដែលបានរៀបការជាមួយគ្នានៅក្នុងឆ្នាំ២០១១ ព្រមទាំងបានកូនប្រុសមួយ ស្រីមួយ , ហើយបន្តមកទៀត [redacted] ច័ន្ទលីដូ បានរកឃើញមានស្ត្រីខាងក្រៅ រហូតដល់មានកូនទៀត ព្រមទាំងបានជួយទំនុកបំរុងជានិច្ច រហូតដល់ [redacted] ច័ន្ទលីដូ កើតមានក្ដីខកចិត្តរហូតដល់ការរំលាយអាពាហ៍ពិពាហ៍ ដែលមានខ្លឹមសារស្នើសុំលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម រដ្ឋប្បវេណីលេខ ១២៦៥ “ឈ” ភ.ព.រ.វ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ហើយបានចូលជាស្ថាពរនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ។ ពាក់ព័ន្ធជាមួយផ្ទះលេខ C53 ភូមិទឹកថ្លា មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ផ្ទះនេះមានប្រវត្តិដូចតទៅ ៖ បន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ ឈ្មោះ [redacted] ច័ន្ទសុទ្ធា នឹង [redacted] ច័ន្ទលីដូ កូនក្ដីរបស់ខ្លួនសុទ្ធតែជាអ្នករកស៊ី អ៊ីចឹងមានការលំបាកក្នុងការរត់ឯកសារ និងបញ្ជាក់ប្រភពចំណូលដើម្បីទិញផ្ទះ ការទិញផ្ទះ គឺឈរឈ្មោះ [redacted] ច័ន្ទសុទ្ធា និង [redacted] ច័ន្ទលីដូ តែតាមពិតផ្ទះនោះគឺជារបស់ប៉ាម៉ាក់របស់កូនក្ដីខ្លួន គឺឈ្មោះ [redacted] ច័ន្ទលីដូ ជាអ្នកទិញ ។ បន្ទាប់ពីបានធ្វើការបញ្ជាក់បានលុយបង់ដំណាក់កាលបន្តបន្ទាប់រហូតដល់ឆ្នាំ២០១៣ ក៏ប្រមែប្រមូលលុយនឹងខ្ចីលុយបងប្អូនផ្សេងៗទាំងអស់យកមកបង់ផ្ទះផ្ដាច់ បានន័យថា ផ្ទះដំបូងនេះបង់ដំបូងផ្ដាច់ហើយ បន្តមកទៀត [redacted] ច័ន្ទសុទ្ធា ក៏បានលួងលោម [redacted] ច័ន្ទលីដូ ខ្ចីយកទៅដាក់ធនាគារបន្តបន្ទាប់ សរុបទាំងអស់ ៩ ម៉ឺនក្នុងការសងលុយធនាគារសរុបគ្នាសងរួមគ្នាបានតែ ១ ម៉ឺនទេ គឺនៅសល់ ៨ ម៉ឺនទៀត ។ កូនក្ដីរបស់ខ្លួន [redacted] ច័ន្ទលីដូ បានរកឃើញថា អតីតស្វាមីរបស់ខ្លួនលួចមានស្ត្រី និងមានកូន រហូតដល់កើតក្ដីឈឺចិត្ត បាន



Scanned with CamScanner

ដាក់ពាក្យបណ្តឹងលែងលះ ។ អំពីអង្គហេតុរបស់ឈ្មោះ [redacted] ផល្លី តាមពាក្យបណ្តឹង ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២០១៦ ដែលបានចោទប្រកាន់មកលើកូនក្តីខ្លួនពីបទសមគំនិត និងអំពើទទួលផលចោរកម្ម ទៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដោយបានចោទប្រកាន់តាមមាត្រា ២៩, មាត្រា ៣៩១ ,មាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។ តាមពាក្យ បណ្តឹងតាំងពីនៅសាលាដំបូង និងសាលាឧទ្ធរណ៍ គឺមាន ៤ ប៉ុណ្ណោះ គឺ (១)អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន (២)ប័ណ្ណសម្គាល់បុគ្គលិករបស់ឈ្មោះ [redacted] ច័ន្ទសុទ្ធា (៣) កិច្ចសន្យាលក់ទិញដីសម្រាប់សាងសង់ផ្ទះល្វែងរបស់ជនជាប់ចោទ និង(៤) សាលក្រមស្តាពរស្តីពីការលែងលះគ្នា ។

សំណូមពរ ៖ សូមឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាលើឈ្មោះ [redacted] ច័ន្ទលីជូ ដែលជាក្មេងស្រីម្នាក់ ដែលរកស៊ីនៅផ្ទះពុំមានតួនាទី មិនមែនជាបុគ្គលិក ហើយក៏មិនដែលបានចូលរួមធ្វើសកម្មភាពណាមួយជាមួយក្រុមហ៊ុនសេះមាស ដូចដែលឈ្មោះ [redacted] ផល្លី អះអាងនោះទេ ។

បើពិនិត្យលើមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌបានចែងថា ចាត់ទុកថាអ្នកសមគំនិត ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង និងសម្រេចពីបទឧក្រិដ្ឋ បទមជ្ឈិម នឹងផ្តល់ជំនួយដោយអំពើរបស់ខ្លួន ថាតើនារីម្នាក់ដែលមានតួនាទីជាស្ត្រីមេផ្ទះ នៅផ្ទះ រកស៊ីតិចតួចនៅក្រៅ តើមានលទ្ធភាពឯណាជួយសម្រួលដល់ការប្រព្រឹត្តបទល្មើស ដែលប្រព្រឹត្តនៅទីតាំងរបស់ក្រុមហ៊ុនដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ ដែលមិនមានតួនាទីអ្វីសោះ ហើយមិនមែនជាបុគ្គលិកទាល់តែសោះ តើអាចសម្រួលដោយវិធីណា ?

ពាក់ព័ន្ធនឹងករណីនេះឃើញថា តាំងពីដើមមកឈ្មោះ [redacted] ច័ន្ទសុទ្ធា មិនដែលបានចូលមកតតាំងការពារសិទ្ធិរបស់ខ្លួនពាក់ព័ន្ធនឹងបណ្តឹងនេះទេ គឺរត់ចោលផ្ទះ តាំងពីនៅសាលាដំបូងរាជធានីភ្នំពេញ និងនៅសាលាឧទ្ធរណ៍ រហូតមកដល់តុលាការកំពូលនេះទៀត គឺរត់ចោលផ្ទះតាំងពីពេលនោះមក ប្រហែល ៥ ឆ្នាំមកហើយ ។

ភស្តុតាងដាក់បន្ទុកផ្សេងៗសុទ្ធតែបានលើកឡើងដោយឯកតោភាគីរបស់ដើមបណ្តឹងរដ្ឋប្បវេណី មកទល់ពេលនេះមិនទាន់មានការវិនិច្ឆ័យការស្រាវជ្រាវណាអះអាងថា បាត់លុយ បាត់ដោយវិធីណា ហើយកូនក្តីរបស់ខ្លួនឈ្មោះ [redacted] ច័ន្ទលីជូ បានដឹងលឺដោយវិធីណា បានចូលរួមសមគំនិត ជួយសម្រួលដោយវិធីណាដែលគួរឱ្យជឿ ក៏អត់មានទាំងអស់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ នឹងដើម្បីជៀសវៀងការវិនិច្ឆ័យទោសដល់ជនដែលពុំបានចូលរួមដឹងលឺប្រព្រឹត្តអំពើល្មើសនេះទេ នឹងប៉ះពាល់សិទ្ធិសេរីភាពមូលដ្ឋានរបស់ប្រជាពលរដ្ឋ ក្នុងនាមខ្លួនជាមេធាវីការពារក្តីឱ្យ [redacted] ច័ន្ទលីជូ សូមសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចបដិសេធចោលសាលដីកាព្រហ្មទណ្ឌលេខ ២០ក្រII "វ" ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ និងសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] ច័ន្ទលីជូ រួចផុតពីបទចោទប្រកាន់ពីពេលនេះតទៅ ។

-លោក [redacted] ច័ន្ទតារាវុធ ជាមេធាវីការពារបានធ្វើសេចក្តីសន្និដ្ឋានថា៖ ខ្លួនជាមេធាវីការពារក្តីឱ្យ [redacted] ច័ន្ទលីជូ កូនក្តីខ្លួនបានដាក់ពាក្យបណ្តឹងសាទុក្ខមកតុលាការកំពូលនេះដោយហេតុថា សាលាឧទ្ធរណ៍បានសម្រេចសេចក្តីនៅចំណុចមួយដែលបានបំភ្លៃលើអង្គហេតុ និងបានប្តឹងសាទុក្ខមកតុលាការកំពូលដើម្បី



Scanned with CamScanner

ឱ្យតុលាការកំពូលជួយរកយុត្តិធម៌ឱ្យកូនក្តីខ្លួនដែលជាជនស្លូតត្រង់នេះ ពុំបានចូលរួមប្រព្រឹត្តនិងសមគំនិត ដូចដែលសាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ បានធ្វើការសម្រេចសេចក្តីនេះទេ ។ ដូច្នេះខ្លួនសូមឡើងបញ្ជាក់បន្ថែម ចំពោះផ្ទះមិនមែនរស់នៅតែពីរនាក់ប្តីប្រពន្ធទេ គឺរស់នៅជាមួយគ្រួសារទាំងអស់ គឺប្តីប្រពន្ធ កូន ប្អូនស្រី ប្អូនប្រុសពីរនាក់ទៀត។ ក្នុងគ្រួសារទាំងអស់ជាអ្នករកស៊ី ដូចនេះពុំមានលទ្ធភាពណាបង់រំលស់នោះទេ ចំពោះការបង់រំលស់ត្រូវតែមានឯកសាររឹងមាំ ហេតុនេះតម្រូវឱ្យឈ្មោះ [redacted] ច័ន្ទសុទ្ធា ឈររឈ្មោះ ហើយរាល់ការចំណាយទាំងអស់គឺក្រុមគ្រួសាររបស់ [redacted] ច័ន្ទលីជូ ជាអ្នកចេញលើការបង់រំលស់ផ្ទះ ។

-លោក [redacted] វណ្ណាយ ជាមេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្នុងនាមខ្លួនជាមេធាវីតំណាងឱ្យឈ្មោះ [redacted] ផល្លី សូមធ្វើការសន្និដ្ឋានពាក់ព័ន្ធនឹងសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ និងសាលដីការបស់សាលាឧទ្ធរណ៍ពិតជាមានលក្ខណៈគ្រប់គ្រាន់ដែលជនជាប់ចោទទាំងពីរនាក់ គឺ [redacted] ច័ន្ទលីជូ និង [redacted] ច័ន្ទសុទ្ធា បានប្រព្រឹត្តបទល្មើសរំលោភលើទំនុកចិត្ត ដោយសាររឿងក្តីនេះនៅក្នុងតុលាការអង្គច្បាប់ សូមឱ្យតុលាការវិនិច្ឆ័យទៅតាមអ្វីដូចនៅក្នុងសារណាដែលបានបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខដាក់ជូនមកតុលាការកំពូលនេះ ដែលបានបញ្ជាក់អំពីអង្គច្បាប់ពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ ពិតជាបានប្រព្រឹត្តអំពើសមគំនិតដូចដែលមានចែងក្នុងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

សំណូមពរ៖ ក្នុងនាមខ្លួនជាមេធាវី សូមស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះតម្កល់សាលដីកាលេខ ២០ក្រII "វ" ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

-លោក [redacted] សាវុឌ្ឍី ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្នុងនាមខ្លួនជាមេធាវីតំណាងឱ្យ [redacted] ផល្លី សូមធ្វើសេចក្តីថ្លែងហេតុ រាល់ការប្រមូលចំណូល និងចំណាយ កាលមិនទាន់មានប្រពន្ធ ឈ្មោះ [redacted] ច័ន្ទសុទ្ធា ធ្វើការបានល្អ តែនៅពេលចាប់ផ្តើមមានប្រពន្ធការងាររបស់ [redacted] ច័ន្ទសុទ្ធា ចាប់ផ្តើមមានការរអាក់រអួល រហូតដល់មានការសង្ស័យ ក៏បានស្រាវជ្រាវរកឃើញថា ឈ្មោះ [redacted] ច័ន្ទសុទ្ធា បានទិញផ្ទះ ។ ដូច្នេះផ្ទះជាតម្រូវដែលបញ្ជាក់អំពីអំពើរំលោភលើទំនុកចិត្ត ដែលជារបាយការណ៍របស់ក្រុមហ៊ុនដែលគេវាយតម្លៃ នៅ [redacted] សុទ្ធា មិនយកលុយមកដាក់នៅក្នុងក្រុមហ៊ុនជាង ១២ ម៉ឺន ។ ទាក់ទងនឹងឈ្មោះ [redacted] ច័ន្ទលីជូ បានលើកឡើងថា មិនមានភស្តុតាងណាបញ្ជាក់ តែពាក់ព័ន្ធនឹងផ្ទះនេះហើយ គឺជាភស្តុតាង នឹងតម្រុយ ។

សំណូមពរ៖ សូមឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការទាំងស្រុង ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យជនជាប់ចោទ និងមេធាវីការពារក្តី និងមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## សំអាងហេតុ

### តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៥៧ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជួ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងក្តីនេះមកជំនុំជម្រះបាន យោងតាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាមត្រា៤១៧, ៤១៨ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ការដែលសាលាដំបូងរាជធានីភ្នំពេញ និងសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បានសម្រេចប្រកាសទោសលើជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជួ ពីបទសមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅត្រង់ចំណុចក្រុមហ៊ុនសេះមាស និងក្រុមហ៊ុន អេសឃេអេ ផ្ទះលេខ AH1-2-3 ភូមិក្បាលដំរី សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥ តាមបទប្បញ្ញត្តិមាត្រា២៩, មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ដោយសំអាងហេតុថា តាមការពិនិត្យទៅលើអង្គហេតុឃើញថា មានភាពស៊ីសង្វាក់នឹងពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបញ្ជាក់ថា នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥ ក្រុមហ៊ុនបានរកឃើញថា ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទសុទ្ធា បានលួចលុយរបស់ក្រុមហ៊ុនយកទៅឱ្យជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជួ ដើម្បីទិញផ្ទះលេខ C-53 មហាវិថីសហព័ន្ធរុស្សី ផ្លូវឈៀហ្វលណេស ភូមិទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញប្រាកដមែននោះ តុលាការកំពូលពិចារណាឃើញថា សំអាងហេតុនេះពុំមានមូលដ្ឋានអង្គហេតុ ភស្តុតាងសមស្រប ដើម្បីកំណត់ពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជួ នោះទេ ពីព្រោះថា តាមបទបញ្ញត្តិមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ ដើម្បីអាចចាត់ទុកថា ឈ្មោះ [redacted] ច័ន្ទលីជួ ជាអ្នកសមគំនិតក្នុងអំពើល្មើសណាមួយ លុះត្រាតែជននេះបានជួយសម្រួលដោយចេតនា ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភជាមុន ឬក្នុងពេលដែលចារីប្រព្រឹត្តបទល្មើស ប៉ុន្តែក្នុងរឿងក្តីនេះពុំមានភស្តុតាងណាមួយដែលបញ្ជាក់អំពីអង្គហេតុថា ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជួ បានផ្តល់ជំនួយ ឬឧបត្ថម្ភដល់ចារី ក្នុងការប្រព្រឹត្តបទល្មើសរំលោភលើទំនុកចិត្ត ស្របតាមបទបញ្ញត្តិមាត្រា២៩ នេះឡើយ ។

៣-យល់ឃើញថា ក្នុងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ក៏ដូចជាសេចក្តីសន្និដ្ឋានផ្ទាល់មាត់នាពេលសវនាការរបស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងថា ឈ្មោះ [redacted] ច័ន្ទលីជួ មិនមែនជាបុគ្គលិកបម្រើការងារនៅក្នុងក្រុមហ៊ុននោះទេ ដូច្នេះគ្មានលទ្ធភាពក្នុងការជួយសម្រួល ផ្តល់ជំនួយ ដូចមានចែងកក្នុងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌនោះទេ ។ ពុំមានភស្តុតាងបញ្ជាក់ ឬបង្ហាញថាឈ្មោះ [redacted] ច័ន្ទលីជួ បានប្រព្រឹត្តអំពើសមគំនិតជាមួយនឹងឈ្មោះ [redacted] ច័ន្ទសុទ្ធា នោះទេ ។ កិច្ចសន្យាលក់ទិញផ្ទះ និងទំនាក់ទំនងអាពាហ៍ពិពាហ៍ មិនមែនជាភស្តុតាងបញ្ជាក់អំពីអំពើសមគំនិតក្នុងបទល្មើសរំលោភលើទំនុកចិត្តនេះទេ ។ ពុំមានធាតុផ្សំនៃបទល្មើសតាមបទប្បញ្ញត្តិមាត្រា ៣៩១,មាត្រា៣៩២ និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌឡើយ ។ យោងតាមបទប្បញ្ញត្តិមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញបញ្ញត្តិថា "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់



Scanned with CamScanner

ចោទ" ។ ដែលសេចក្តីសន្និដ្ឋាននេះរបស់តំណាងមហាអយ្យការសមស្របទៅនឹងសំអាងហេតុរបស់អង្គជំនុំជម្រះ ដែលអង្គជំនុំជម្រះអាចទទួលយកជាមូលដ្ឋានក្នុងពិចារណា វិនិច្ឆ័យ សម្រេចសេចក្តីក្នុងរឿងក្តីនេះបាន ។

៤-យល់ឃើញថា តាមសំអាងហេតុត្រង់ចំណុចទី២ និងទី៣ ខាងលើ បង្ហាញឱ្យឃើញថា គ្មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ ពីបទសមគំនិតក្នុងអំពើវិលោភលើទំនុចចិត្ត ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនសេះមាស និងក្រុមហ៊ុន អេសឃេអេ ផ្ទះលេខ AH1-2-3 ភូមិក្បាលដំរី សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា២៩,មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ដែលតុលាការកំពូលគប្បីសម្រេចឱ្យឈ្មោះ [redacted] ច័ន្ទលីជូ រួចខ្លួនពីបទចោទប្រកាន់ តាមប្បញ្ញត្តិមាត្រា ៣៥០ កថាខណ្ឌទី៣ និងមាត្រា ៤៤០ នៃក្រមនីតិវិធីព្រហមទណ្ឌ ។

៥-យល់ឃើញថា សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី មិនមានខ្លឹមសារត្រង់ចំណុចណាមួយបង្ហាញឱ្យតុលាការកំពូលពិចារណាឃើញថា ពិតជាកើតមាននូវអង្គហេតុនៃអំពើសមគំនិតរបស់ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ ពីបទសមគំនិតក្នុងអំពើវិលោភលើទំនុកចិត្តប្រព្រឹត្តដោយជនឈ្មោះ [redacted] ច័ន្ទសុទ្ធា នោះឡើយ ដូចការដែលអង្គជំនុំជម្រះបានលើកបង្ហាញនៅក្នុងសំអាងហេតុត្រង់ចំណុចទី២ ខាងលើនេះ ។

៦-យល់ឃើញថា តាមបទប្បញ្ញត្តិមាត្រា ២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការព្រហ្មទណ្ឌពុំអាចសម្រេចឱ្យជនជាប់ចោទទទួលខុសត្រូវខាងសំណងរដ្ឋប្បវេណីបានទេ ដោយហេតុថា តុលាការកំពូលរកមិនឃើញមានពិរុទ្ធភាពលើជនជាប់ចោទ ។

៧-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២០ ក្រII "វ" ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ និងសាលក្រមព្រហ្មទណ្ឌលេខ ៣៤៣៧ "ញ" ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចសេចក្តីពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] ចន្ទលីជូ ពុំត្រឹមត្រូវតាមគតិច្បាប់ឡើយ ។

**ហេតុដូច្នេះ**

**សម្រេចសេចក្តី**

១-ទទួល បណ្តឹងសាទុក្ខលេខ ៥៧ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់។

២-បដិសេធ សាលដីកាព្រហ្មទណ្ឌលេខ ២០ ក្រII "វ" ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ និងសាលក្រមព្រហ្មទណ្ឌលេខ ៣៤៣៧ "ញ" ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្តីសម្រេចពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ ។

៣-ឱ្យជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ រួចខ្លួនពីបទចោទប្រកាន់ បទសមគំនិតក្នុងអំពើវិលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនសេះមាស និងក្រុមហ៊ុន អេសឃេអេ ផ្ទះលេខ AH1-2-3 ភូមិក្បាលដំរី



Scanned with CamScanner

សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌមានចែងនិងឱ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា២៩,មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ និងតាមបទប្បញ្ញត្តិម្ភាវា ៣៥០ ត្រង់កថាខណ្ឌទី៣ និងមាត្រា៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤-ឱ្យជនជាប់ចោទឈ្មោះ [redacted] ច័ន្ទលីជូ រួចផុតពីការទទួលខុសត្រូវខាងសំណងរដ្ឋប្បវេណី ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រ ទី១៧ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃសុក្រ ទី២៤ ខែមករា ឆ្នាំ២០២០ ។

Scanned with CamScanner